- **គ្មានប្រាក់ចំណូល:** បើលោកអ្នកគ្មានប្រាក់ចំណូលអ្វីទេនោះ សូមផ្ញើរលិខិតយ៉ាងខ្លីមួយច្បាប់ ពន្យល់ថាតើលោកអ្នកទិញម្ហូបអាហារ សម្លៀកបំពាក់ និងចេញថ្លៃផ្ទះ សម្រាប់គ្រួសារលោកអ្នក តាមវិធីណា ហើយនិងថា នៅពេលណាទើបលោកអ្នក រំពឹងថា និងមានប្រាក់ចំណូល១នោះ ។

សេចក្តីថ្លែងអំពីច្បាប់ចែងពីរឿងសម្ងាត់ផ្ទាល់ខ្លួន: ជៀសវាងតែលោកអ្នកកត់លេខប្រាក់Food Stamp, លេខប្រាក់ជំនួយសម្រាប់អ្នករស់នៅក្នុងកន្លែងជនជាតិ ស្បែកក្រហម(FDPIR) ឬ លេខករណីប្រាក់ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារខ្វះខាតនោះចេញ (TANF), មាត្រាទី៩ នៃច្បាប់ចែងពីការទទួលទាន ចំណីអាហារ ពេលថ្ងៃត្រង់ នៅសាលារៀន តម្រូវឱ្យលោកអ្នកចុះលេខ សន្តិសុខសង្គម (social security number) របស់បុគ្គលនិមួយៗ ក្នុងគ្រួសារ ដែលចុះហត្ថលេខា នៅលើសំណុំពាក្យ ឬ កត់សម្គាល់ថា សមាជិកដែលចុះហត្ថលេខាលើពាក្យនោះ គ្មានលេខសន្តិសុខសង្គមទេ ។ លោកអ្នកមិនចាំបាច់ចុះលេខសន្តិសុខសង្គមទេ ក៏ប៉ុន្តែ បើសិនជាគ្មានការចុះលេខនេះទេ ឬ បើគ្មានការបញ្ជាក់ថា សមាជិកពេញវ័យ នៃគ្រួសារដែលចុះហត្ថលេខានៅលើពាក្យនេះ គ្មានលេខសន្តិសុខសង្គមទេនោះ, យើងខ្ញុំមិនអាចអនុមត្តិលើសំណុំពាក្យនេះបានទេ ។ លេខសន្តិសុខសង្គម អាចយកទៅប្រើប្រាស់ដើម្បីសម្គាល់ សមាជិកគ្រួសារ ក្នុងការផ្ទៀងផ្ទាត់មើល ភាពត្រឹមត្រូវជាក់លាក់ នៃពត៌មាន ដែលចុះក្នុងពាក្យនេះ ។ ការពិនិត្យមើលនេះ អាចរួមបញ្ចូលទាំងការពិនិត្យសើរើមើលឡើងវិញ នូវកម្មវិធី, ការជម្រះបញ្ជី និងការស៊ើបអង្កេត ហើយថែមទាំងមានរួមទាំង ការទាក់ទងជាមួយនិង និយោជក ដើម្បីសម្រេចឱ្យដឹង នូវប្រាក់ចំណូល, ការទាក់ទងនិង ការិយាល័យ FOOD STAMP , ការិយាល័យ FDPIR ឬ ការិយាល័យ TANF ដើម្បីសម្រេចនូវ ការបញ្ជាក់អះអាង ចំនួនប្រាក់ FOOD STAMP, ប្រាក់ FDPIR ឬ ប្រាក់ TANF, ការទាក់ទង ជាមួយការិយាល័យ សន្តិសុខការងារ របស់រដ្ឋ ដើម្បីសម្រេចនូវចំនួនប្រាក់កម្រៃ ដែលបានទទួល និងឆែកឆេរមើល ឯកសារ របស់សមាជិកគ្រួសារ ដើម្បីបញ្ជាក់ថា ចំនួនប្រាក់ចំណូល ដែលបានទទួលនោះ ពិតប្រាកដត្រឹមត្រូវមែន ។ កិច្ចប្រឹងប្រែងទាំងនេះ ប្រហែលជាអាចនាំឱ្យមានការបាត់បង់ ឬ ការកាត់បន្ថយ ផលកម្រៃ, ការប្រកាន់របស់រដ្ឋបាល ឬ សកម្មភាពខាងផ្លូវច្បាប់ផង បើសិនមានសេចក្តីរាយការពត៌មាន មិនត្រឹមត្រូវនោះ ។ លេខសន្តិសុខសង្គម ប្រហែលជាអាចបញ្ជូនទៅឱ្យកម្មវិធីទាំងឡាយ ដូចដែលបានទទួលការអនុញ្ញាត្ត នៅក្រោមច្បាប់ម្ហូបអាហារសាលាជាតិ និង ច្បាប់ជីវជាតិអាហារកូនក្មេង, ទាយកអ្នកកាន់លុយកាក់ នៃសហរដ្ឋអាមេរិក និង ក្រុមមន្ត្រីអនុវត្តិច្បាប់ ក្នុងគោលបំណង នៃការស៊ើបអង្កេត បទល្មើសលើ កម្មវិធីណា១ ខាងផ្នែកសិក្សាអប់រំសុខភាព និងជីវជាតិអាហារ របស់រដ្ឋាភិបាល សហពន្ធ័រដ្ឋ និងស្រុកណាមួយនោះ ។